00782525

E169/2

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 02 / 2012
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២

**ជូនចំពោះ:** **អ្នកជំនាញ** TCE-33

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ភាគីនៃសំណុំរឿង ០០២, អង្គភាពគាំពារសាក្សី និង អ្នកជំនាញ**

**កម្មវត្ថុ:** **សំណើសុំព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសង្ខេបនៅក្នុងសំណុំរឿង ០០២**

សំណុំឯកសារនៃសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ មានសេចក្តីសង្ខេបនៃឯកសារចំនួន ០២ ដែលសហព្រះរាជអាជ្ញាបានបង្ហាញក្នុងលក្ខណៈជាសេចក្តីសង្ខេបដែលលោកបានរៀបចំ (សូមមើលឯកសារ E169/1)៖

- សេចក្តីសង្ខេបនៃទស្សនាវដ្តីយុវជនបដិវត្តន៍, លេខចេញផ្សាយ ខែ កក្កដា ឆ្នាំ ១៩៧៥ (ឯកសារ IS11.1)
- សេចក្តីសង្ខេបនៃទស្សនាវដ្តីទង់បដិវត្តន៍, លេខចេញផ្សាយ ខែ ធ្នូ ឆ្នាំ ១៩៧៥ - ខែ មករា ឆ្នាំ ១៩៧៦ (ឯកសារ IS11.5)។

អង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យលោកបញ្ជាក់៖

- ថាតើលោកពិតជាអ្នករៀបចំសេចក្តីសង្ខេបដែលភ្ជាប់មកជាមួយនេះមែនដែរឬទេ

- ហេតុអ្វីលោករៀបចំសេចក្ដីសង្ខេបនេះ (ហើយថាតើលោករៀបចំតាមគំនិតផ្ទាល់ខ្លួន ឬតាមសំណើ)
- ទីតាំងនៃឯកសារដែលលោកបានសង្ខេបនោះ
- តើបច្ចុប្បន្នឯកសារដែលលោកបានសង្ខេប អាចរកបានដែរឬទេ
- ប្រសិនបើឯកសារដែលលោកសង្ខេបនោះជាឯកសារថតចម្លង សូមលោកបញ្ជាក់ថាតើបច្ចុប្បន្នឯកសារដើមអាចរកបានដែរឬទេ។

អង្គជំនុំជម្រះសាលាដំបូងស្នើសុំឱ្យលោកផ្ដល់ព័ត៌មានទាំងនេះត្រឹមថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២។

ការប្រាស្រ័យទាក់ទងណាមួយ គួរធ្វើតាមរយៈ៖
លោកស្រី Wendy Lobwein
មន្ត្រីសម្របសម្រួល, អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ប្រអប់សំបុត្រ PO Box. 71
ភ្នំពេញ
កម្ពុជា

លោកគួរផ្ញើសំណៅស្កែនទៅលោកស្រី Lobwein ផងដែរតាមរយៈសារអេឡិចត្រូនិក (lobwein@un.org) ដោយចម្លងជូនលោកស្រី Sophie Swart (swarts@un.org)។

ឯកសារភ្ជាប់៖
-សំណើសុំព័ត៌មានពាក់ព័ន្ធនឹងសេចក្ដីសង្ខេបដែលអ្នកជំនាញ TCE-33 បានរៀបចំ (ឯកសារ E169)
-ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំព័ត៌មានពាក់ព័ន្ធនឹងសេចក្ដីសង្ខេបដែលអ្នកជំនាញTCE-33 បានរៀបចំ" (ឯកសារ E169/1)
-សេចក្ដីសង្ខេបនៃទស្សនាវដ្ដីយុវជនបដិវត្តន៍, លេខចេញផ្សាយ ខែ កក្កដា ឆ្នាំ ១៩៧៥ (IS11.1)
-សេចក្ដីសង្ខេបនៃទស្សនាវដ្ដីទង់បដិវត្តន៍, លេខចេញផ្សាយ ខែ ធ្នូ ឆ្នាំ ១៩៧៥-ខែ មករា ឆ្នាំ ១៩៧៦ (IS 11.5)។